00637107

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E19/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 01 / 2011
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# ដីកាកំណត់កាលបរិច្ឆេទសវនាការទាក់ទងនឹងសំណើសុំឲ្យដោះលែង នួន ជា ជាបន្ទាន់

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
សា សូវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · E C C C

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

**បានឃើញ** សំណើសុំឱ្យដោះលែង នួន ជា ជាបន្ទាន់ ដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា ("មេធាវី") កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ ("សំណើ")។

**អនុលោម** តាមវិធាន ៧៩ និងវិធាន ៨២ នៃវិធានផ្ទៃក្នុង។

## ហេតុដូច្នេះសម្រេច

**ទទួល** យកសំណើសុំរបស់មេធាវីការពារក្តីដើម្បីដាក់ជេញដោលនៅក្នុងសវនាការផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ នៅបន្ទប់សវនាការធំនៃ អ.វ.ត.ក ចាប់ពីម៉ោង ៩ និង ៣០ នាទីព្រឹកតទៅ។

**ស្នើឱ្យ** សហព្រះរាជអាជ្ញាឆ្លើយតបដោយផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្តីនៅក្នុងអំឡុងពេលសវនាការ ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងធ្វើដូច្នេះ។ បន្ទាប់មក មេធាវីការពារក្តីនឹងត្រូវអនុញ្ញាតឱ្យធ្វើការឆ្លើយតបភ្លាម។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេច បន្តចិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE C.C.E.T.C.

កត់សម្គាល់ថា វិធាន ៨២(៣) នៃវិធានផ្ទៃក្នុងកំណត់ការចូលរួមសវនាការត្រឹមតែភាគីដែលពាក់ព័ន្ធនឹងសំណើសុំប៉ុណ្ណោះ។ វិធាននេះមិនតម្រូវឱ្យមានការធ្វើការកត់សម្គាល់ពីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏មិនតម្រូវឱ្យមានវត្តមានពួកគេក្នុងសវនាការដែរ។

ភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

E C C C

និល ណុន